## ការអំពាវនាវជាសកលដើម្បីបញ្ចូលបេតិកភណ្ឌវប្បធម៌, សិល្បៈ និងវិស័យច្នៃប្រឌិត ជាបេះដូងនៃការសកម្មភាពអាកាសធាតុ

# ដំណើរការនៃការរៀបចំយុទ្ធនាការ *Call to Action* នេះ ត្រូវបានដាក់ឲ្យដំណើរការ នៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២៣ អំឡុងកិច្ចប្រជុំកំពូល បេតិកភណ្ឌ វប្បធម៌អឺរ៉ុប ដែលធ្វើឡើងនៅក្នុងទីក្រុងវេនីស នៃប្រទេសអ៊ីតាលី ក្នុងវេទិកាបេតិកភណ្ឌអឺរ៉ុប *«Reimagining the Anthropocene:* ការដាក់វប្បធម៌ និងបេតិកភណ្ឌ ជាបេះដូងនៃការសកម្មភាពអាកាសធាតុ។

យុទ្ធនាការនេះ ពិតជាវិធីដ៏មានសារៈសំខាន់ណាស់
ដើម្បីឆ្ពោះទៅរកដំណោះស្រាយចល័តប្រកបដោយភាពច្នៃប្រឌិតសម្រាប់ដោះស្រាយវិបត្តិអាកាសធាតុ។

យើងបានចុះកិច្ចព្រមព្រៀងស្នើរសុំឱ្យរដ្ឋាភិបាលជាតិ ដែលជាភាគីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ**(UNFCCC)**និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសរបស់ខ្លួន ដើម្បីអនុម័តសេចក្តីសម្រេច**‘Joint Work on Culture and Climate Action’** ដែលសម្រេចដោយ**(JWD)** នៅ **COP** ។

ការសម្រេចចិត្តនេះនឹងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ **UNFCCC** សម្រាប់ចាប់ផ្តើមដំណើរការ, ការពិគ្រោះយោបល់ដើម្បីចូលរួមចំណែកយ៉ាងពេញទំហឹងនៃវប្បធម៌ រួមទាំងបេតិកភណ្ឌវប្បធម៌, សិល្បៈ និងវិស័យច្នៃប្រឌិត ចំពោះសកម្មភាពអាកាសធាតុ។ ដំណើរការនេះនឹងពិនិត្យមើលថាតើការឆ្លើយតបអាកាសធាតុដែលដឹកនាំដោយវប្បធម៌បាននឹងកំពុងកើតឡើង ហើយឬនៅ, នៅកន្លែងណា, ដោយនរណា នឹងចែករំលែករាល់មតិយោបល់ ដើម្បីពង្រីកបន្ថែមនូវដំណោះស្រាយផ្អែកលើវប្បធម៌ ដោយអាចជួយធានាបានថា វប្បធម៌ត្រូវបានចូលរួមយ៉ាងពេញទំហឹងទៅលើការងារនាពេលអនាគតនៃអនុសញ្ញានេះ។

វប្បធម៌មានសមត្ថភាពមិនអាចប្រៀបផ្ទឹមបានដើម្បីធ្វើការផ្លាស់ប្តូរ

## វប្បធម៌ចម្រុះនៅលើពិភពលោកមានឥទ្ធិពលទៅលើមនុស្សគ្រប់គ្នា, គ្រប់ទីកន្លែង, រួមបញ្ចូលនូវការបញ្ចេញមតិ, ទស្សនៈ និងឧបករណ៍ដើម្បីធ្វើការទំនាក់ទំនងជាបន្ទាន់,

សកម្មភាពចល័ត និងការសម្រេចបានគោលដៅនៃការរស់នៅប្រកបដោយនិរន្តរភាព និងយុត្តិធម៌។ តាមរយៈវត្តមាននៃការចូលរួមពីវប្បធម៌, ការការពារ, កិច្ចពិភាក្សា, បទពិសោធន៍, រឿងតំណាល, ព្រឹត្តិការណ៍ និងការផ្តល់ជូនប្រកបដោយរូបភាពច្នៃប្រឌិតវប្បធម៌ពិតជាមានឥទ្ធិពលយ៉ាងខ្លាំង ជាពិសេសនៅពេលដែលត្រូវបានពង្រឹងដោយការគោរពសិទ្ធិវប្បធម៌។

ចំណងថាមពលនៃតម្លៃវប្បធម៌ចម្រុះ និងវិធីនៃការយល់ដឹង, ការអប់រំ និងការតំណាលរឿងតៗគ្នា, សិល្បៈ និងសិប្បកម្ម, បេតិកភណ្ឌរូបី និងអរូបី ព្រមទាំងគំនិតនៃការច្នៃប្រឌិតអាចជួយតម្រង់ផ្លូវ និងពង្រីកសកម្មភាពនោះ ដើម្បីធ្វើការផ្លាស់ប្តូរប្រព័ន្ធណាដែលចាំបាច់ និងដើម្បីដោះស្រាយវិបត្តិអាកាសធាតុ និងវិបត្តិជីវចម្រុះ។

បេតិកភណ្ឌរូបី និងអរូបី ក៏ដូចជាចំណេះដឹងបែបប្រពៃណី, បង្កើនភាពធន់ និងផ្តល់ពេលវេលាសាកល្បង, ការបញ្ចេញឧស្ម័នទាប, បច្ចេកវិជ្ជានៃការបង្កើតឡើងវិញ និងដំណោះស្រាយដែលដើរជារង្វង់ រួមបញ្ចូលទាំងវិស័យសំណង់ និងបរិស្ថានធម្មជាតិ, កសិកម្ម, ថាមពល និងការថែទាំទីជម្រក និងសហគមន៍ផងដែរ។

តម្លៃនៃមនុស្សជាតិគឺសាមគ្គីភាព, ការយកចិត្តទុកដាក់ និងការគោរព, ការខិតខំប្រឹងប្រែងរួមគ្នានៃសិល្បករ, សកម្មជនប្រកបដោយភាពច្នៃប្រឌិត, អ្នករចនា, ស្ថាប័នវប្បធម៌ និងបេតិកភណ្ឌ, សង្គមស៊ីវិល ដែលប្រមូលផ្តុំដោយអ្នកមានជំនាញ និងអ្នកស្ម័គ្រចិត្ត ក៏ដូចជាបញ្ញាវន្ត

និងអ្នកដែរអោយតម្លៃទៅលើចំនេះដឹងរបស់ដូនតា,
អ្នកបង្កើតគោលនយោបាយ, សហគមន៍ និងបណ្ដាជន,
បានផ្ដល់នូវចក្ខុវិស័យ
និងឧទាហរណ៍នៃអនាគតប្រកបដោយនិរន្តរភាព
ដោយមិនពឹងផ្អែកលើឥន្ធនៈហ្វូស៊ីល
ការស្ដារឡើងវិញនូវជីវចម្រុះ នឹងគាំទ្រយុត្តិធម៌សង្គម។

សកម្មភាពអាកាសធាតុផ្អែកលើវប្បធម៌លើកកម្ពស់ដំណោះស្
រាយក្នុងតំបន់ចំពោះបញ្ហាសកល,បំពេញចន្លោះប្រហោងក្នុង
ការរៀបចំផែនការអាកាសធាតុបច្ចុប្បន្នតាមរយៈយុទ្ធសាស្ត្រ
ដែលរួមបញ្ចូល, ដោយផ្អែកលើសិទ្ធិ, ទីកន្លែងជាក់លាក់,
តម្រូវការ និងផ្តោតលើកត្តាប្រជាជន
ក្នុងក្របខ័ណ្ឌដែលទទួលស្គាល់ភាពអាស្រ័យគ្នាទៅវិញទៅម
កនៃភាវៈរស់ទាំងអស់។

ទោះបីជាពុំមានការសង្កត់ធ្ងន់គ្រប់គ្រាន់លើតួនាទីវប្បធម៌នៅក្នុ
ងគោលនយោបាយ
និងការផ្ដល់មូលនិធិផ្លូវការច្រើននៅឡើយក្ដី,
ការបញ្ចេញមតិប្រកបដោយសិល្បៈ
គឺជាក្បាលម៉ាស៊ីននាំមុខនៃបំរែបំរួលទាំង៣ (ធម្មជាតិ,
ប្រព័ន្ធអេឡិចត្រូនិច និងសង្គម),
ការស្វែងរកមធ្យោបាយដើម្បីរក្សាត្រឹមកំរិត១.៥ដឺក្រេ
និងការផ្លាស់ប្ដូរប្រព័ន្ធ។
កង្វះខាតនៃការទទួលស្គាល់គោលការផ្លូវការជារឿយៗ
បានបង្អាក់ការចូលរួមចំណែកដ៏សំខាន់នៃវប្បធម៌
ហើយនៅទីបំផុតពិតជាប៉ះពាល់ដល់សកម្មភាពប្រឆាំងការប្រែ
ប្រួលអាកាសធាតុនៅលើសកលលោកទាំងមូល។

“Joint Work”គឺជាដំណើរការដែលទទួលស្គាល់ដោយ COP
បានស្នើសុំលេខាធិការដ្ឋាន UNFCCC

និងស្ថាប័នពាក់ព័ន្ធដើម្បីឆ្លើយតបទៅហានិភ័យទាំងមតិរិះគន់,
ចំនុចខ្វះខាត។ករណីនេះបានបង្កើតអោយមានចំណុចប្រសព្វ
រវាងវប្បធម៌ និងសកម្មភាពអាកាសធាតុកើតឡើង។
វានឹងត្រួសត្រាយផ្លូវទៅកាន់ការអនុម័តនៅ
COPនាពេលបន្តបន្ទាប់ខាងមុខនៃកម្មវិធីការងារគោលដ៏សំខាន់
មួយ ដើម្បីបញ្ចូលវប្បធម៌ និងបេតិកភណ្ឌ
ជាបេះដូងនៃគោលនយោបាយ, ផែនការ
និងសកម្មភាពអាកាសធាតុ។

សម្រាប់កម្មវិធីគម្រោងនាពេលអនាគតបែបនេះនឹងជួយជំរុញ
ដល់ការយកចិត្តទុកដាក់ទៅដល់សង្គម-វប្បធម៌
ដែលជាល័ក្ខខ័ណ្ឌអាចទៅរួចសម្រាប់សកម្មភាពអាកាសធាតុ
និងគាំទ្រដល់ការកាត់បន្ថយ
និងការបន្សាំដែលមានប្រសិទ្ធភាពជាងមុន។ ទន្ទឹមនឹងនេះ
វានឹងដោះស្រាយបញ្ហាសំខាន់ៗនៃការបាត់បង់
និងការខូចខាតដល់វប្បធម៌
និងបេតិកភណ្ឌដែលត្រូវបានទទួលស្គាល់រួចហើយនៅក្នុងផែ
នការអនុវត្ត Sharm El Sheikh ដែលបានអនុម័តនៅ COP 27។
ជាចុងក្រោយ
វានឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទៅដល់សកលលោកទាំង
មូល
ក្នុងការដាក់វប្បធម៌ជាបេះដូងនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្ត
រភាពដែលធន់នឹងអាកាសធាតុ។

ការបញ្ចូលសំឡេងវប្បធម៌ទៅក្នុងគោលនយោបាយអាកាស
ធាតុអន្តរជាតិនឹងលើកកម្ពស់បេតិកភណ្ឌក្នុងស្រុក
យុទ្ធសាស្រ្តប្រកបដោយសិល្បៈ និងការច្នៃប្រឌិត
អាចផ្តល់នូវមាត្រដ្ឋានត្រឹមត្រូវដើម្បីដោះស្រាយវិបត្តិអាកាស
ធាតុ។

វាក៏នឹងធ្វើអោយមានការគាំទ្រការងាររបស់ជនជាតិភាគតិចបា
នប្រសើរជាងមុនផងដែរ ដែលជាអ្នកថែរក្សា
វប្បធម៌ដ៏យូរយារណាស់មកហើយសម្រាប់មាតុភូមិ។ សរុបមក
វានឹងអាចមានលទ្ធភាពទៅរួចនៃសហគមន៍វប្បធម៌លើសកលលោក ដ៏សម្បូរបែប និងចម្រុះ
ដើម្បីប្រកាសដោយប្រាកដច្បាស់លាស់ និងឯកភាពជាធ្លុងមួយ។
ដូច្នេះការផ្សារភ្ជាប់បណ្តាញទំនាក់ទំនងលើសកលលោកនៃវប្
បធម៌, បេតិកភណ្ឌ, អ្នកតស៊ូមតិ និងអ្នកច្នៃប្រឌិត,
សង្គមស៊ីវិល, ស្ថាប័ន និងស្ថាប័នសាធារណៈគ្រប់លំដាប់ថ្នាក់
ដើម្បីគាំទ្រ UNFCCC ក្នុងបេសកកម្មដ៏សំខាន់របស់ខ្លួន។

ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ
យើងត្រូវតែដោះសោអំណាចផ្លាស់ប្តូរនៃវប្បធម៌ -
ពីសិល្បៈទៅជាបេតិកភណ្ឌ -
ដើម្បីជួយមនុស្សយល់ដឹងពីកាត់បន្ថយឧស្ម័នកាបូន,
ភាពធន់នឹងអាកាសធាតុនាពេលអនាគត ។

យើងបានចុះកិច្ចព្រមព្រៀងដែលមានប្រតិភូចូលរួមទៅកាន់ស
ន្និសិទ្ធអាកាសធាតុរបស់អង្គការសហប្រជាជាតិដើម្បីអនុម័ត
សេចក្តីសម្រេចការងាររួម
ដែលអាចអោយពិភពលោកយើងផ្លូវឆ្ពោះទៅកាន់ការទទួលស្
គាល់វប្បធម៌ជាសសរស្តម្ភដែលមិនអាចខ្វះបាន
ហើយនឹងចូលរួមសកម្មភាពអាកាសធាតុអោយមានប្រសិទ្ធភា
ពជាងមុន។

_______________ **[signatories]**

**END**